## យល់ដឹងខ្លះៗ ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបណ្តែតប្រទីប

**បានផ្សាយនៅ** ថ្ងៃទី 10 ខែ វិច្ឆិកា ឆ្នាំ2015 02:22 PM **ដោយ ៖ អាជ្ញាធរជាតិអប្សរា**




ចាប់ពីថ្ងៃទី២៤ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៥នេះ គឺជាទិវាបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបណ្តែតប្រទីប។ បុណ្យអុំទូក អកអំបុក និងសំពះព្រះខែគឺជាពិធីបុណ្យប្រពៃណីដ៏មានប្រជាប្រិយបំផុតមួយរបស់ប្រជាពលរដ្ឋខ្មែរ។ ជារៀងរាល់ឆ្នាំ នៅទីក្រុងភ្នំពេញមានប្រជាពលរដ្ឋរាប់លាននាក់ ដែលភាគច្រើនឡើងមកពីជនបទបានចូលរួម។

**តើពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបណ្តែតប្រទីបមានទំនាក់ទំនងគ្នាយ៉ាងណាខ្លះ?**

បើមើលតែទៅលើឈ្មោះនៃពិធី យើងនឹងឃើញថា ពិធីទាំងនេះមាននិយមន័យផ្សេងគ្នា ហើយវាមានទិសដៅផ្សេងគ្នាផងដែរ។ ជាទូទៅពិធីបុណ្យអុំទូក ត្រូវបានគេជឿថា ប្រារព្ធធ្វើតាំងពីសម័យបុរាណ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដើម្បីរំឭកដល់គុំវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពជើងទឹកខ្មែរ ដែលបានរំដោះទឹកដីរួចផុតពីការជិះជាន់ របស់ពួកខ្មាំងសត្រូវ(ពួកចាម)។

នៅតាមជញ្ជាំងនៃប្រាសាទ មានចម្លាក់ទាក់ទងទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ទំនៀមទម្លាប់ប្រពៃណី សាសនា សិល្បៈ កីឡា ជាពិសេសការធ្វើសឹកសង្គ្រាមជាមួយពួកចាម ដែលដឹកនាំដោយព្រះបាទជ័យវរ្ម័នទី៧ ទទួលបានជ័យជម្នះយ៉ាងធំធេងតាមរយៈចម្បាំងកងទ័ពជើងទឹក។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺចម្បាំងកងទ័ពជើងទឹក ដែលត្រូវបានគេឆ្លាក់ជាប់នឹងជញ្ជាំងយ៉ាងល្អប្រណីតគួរឲ្យគយគន់ខ្លាំងណាស់។ ចម្លាក់នៃកងទ័ពជើងទឹកនេះត្រូវបានកុលបុត្រខ្មែរជំនាន់ក្រោយ ចងចាំពីគុណបំណាច់របស់បុព្វបុរសខ្លួន ដែលបានរំដោះទឹកដីឲ្យរួចពីការត្រួតត្រារបស់ខ្មាំងសត្រូវ ហើយនាំគ្នាប្រារព្ធធ្វើពិធីអុំទូករំឭកគុណបំណាច់ដ៏ថ្លៃថ្លានេះជារៀងរាល់ឆ្នាំ។ ពិធីនេះ មានតាំងពីសម័យមហាអង្គររហូតមក ហើយប្រជាពលរដ្ឋខ្មែរតែងប្រារព្ធធ្វើពិធីបុណ្យអុំទូក ដើម្បីធ្វើការប្រលងប្រណាំងទូកគ្រប់ប្រភេទ ទាំងបុរស និងស្ត្រី ដែលមកពីគ្រប់ខេត្តក្រុង។

ចំណែកពិធីអកអំបុកសំពះព្រះខែវិញ បើយោងទៅតាមអ្នកកាន់ព្រះពុទ្ធសាសនា គឺជាពិធីមួយ ដែលគេធ្វើឡើងដើម្បីឧទ្ទិសដល់ការបំពេញបុណ្យបារមី របស់ព្រះពោធិសត្វក្នុងពេលដែលយោនយកកំណើតជាសត្វទន្សាយ។ សសបណ្ឌិត ដែលជាទន្សាយពោធិសត្វ បានបូជាខ្លួនប្រាណលោតចូលគំនរភ្លើងដ៏ធំ ដើម្បីចម្អិនសាច់ឲ្យជាអាហារដល់ឥន្ទព្រាហ្មណ៍ ដែលមកប្រាប់ថាខ្លួនអត់អាហារជាច្រើនថ្ងៃមកហើយ។ ការណ៍នេះបានធ្វើឲ្យព្រះឥន្ទយកថ្មទៅគូសជាសត្វទន្សាយ នៅមណ្ឌលព្រះច័ន្ទ។

ពិធីបណ្តែតប្រទីប បើយោងទៅតាមខ្មែរបុរាណ ពិធីនេះជាការសម្តែងនូវការដឹងគុណចំពោះព្រះគង្គា ដែលបានផ្តល់នូវទឹកសម្រាប់ស្រោចស្រពស្រែចម្ការច្បារដំណាំ។ បើតាមអ្នកកាន់ព្រះពុទ្ធសាសនាវិញ ពិធីនេះធ្វើឡើងដើម្បីបូជាដល់ស្នាមព្រះបាទារបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ប្រតិស្ឋាននៅនាស្ទឹងនម្មទា។ ងាកមកមើលប្រវត្តិនៃពិធីនេះ ជាមួយនឹងអ្នកស្រាវជ្រាវផ្នែកបុរាណវិទ្យាវិញម្តង។ **លោក អ៊ឹម សុខរិទ្ធី** អ្នកស្រាវជ្រាវបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា បានពន្យល់ពីខ្លឹមសារនៃពិធីនេះថា ពិធីបុណ្យអុំទូក អកអំបុកសំពះព្រះខែ និងបណ្តែតប្រទីប ដែលយើងមើលទៅឃើញថាផ្សេងពីគ្នានោះ តាមពិតទៅគឺជារឿងតែមួយ ហើយមានទិសដៅតែមួយប៉ុណ្ណោះ។ តាមលោកសាស្ត្រាចារ្យ ពិធីនេះគឺគេធ្វើឡើងទាក់ទងនឹងរឿងធម្មជាតិ។ រឿងធម្មជាតិ ដោយហេតុថា ពិធីនេះគេធ្វើឡើងទាក់ទងនឹងរឿងធ្វើកសិកម្ម។

លោកពន្យល់ថា ការដែលអះអាងថាពិធីនេះមានទំនាក់ទំនងប្រវត្តិសាស្ត្រ ឬសាសនានោះ ក៏ដោយសារឥទ្ធិពលដែលខ្មែរយើងទទួលបានពីឥណ្ឌា ហើយយើងក៏យកមកបកស្រាយតាមក្រោយតែប៉ុណ្ណោះ។ មានមូលដ្ឋានច្រើនដែលអាចបញ្ជាក់ថា ពិធីនេះទាក់ទងនឹងធម្មជាតិ ដោយហេតុថា ខ្មែរបុរាណ ក៏ដូចជាប្រជាជាតិជាច្រើននៅអាស៊ី ក្រោយពីទទួលភោគផលស្រែចម្ការពីធម្មជាតិហើយ ក៏រៀបចំពិធីផ្សេងៗដើម្បីសងគុណចំពោះធម្មជាតិវិញ។

តាម**លោក អ៊ឹម សុខរិទ្ធី** ពិធីអុំទូក និងបណ្តែតប្រទីបជានិមិត្តរូបនៃពិធីបណ្តេញទឹក ត្រឡប់ទៅទន្លេសមុទ្រវិញ ក្រោយពីរដូវវស្សាជាច្រើនខែមក ហើយពិធីអកអំបុកជានិមិត្តរូបនៃភាពបរិបូណ៌នៃភោគផលស្រែដំណាំ។ ឯព្រះចន្ទឬដួងខែជានិមិត្តរូបនៃពន្លឺ ដែលអាចឲ្យគេប្រកបការងារកសិកម្មទៅបាន។ ពិធីបុណ្យអុំទូក សំពះព្រះខែ និងអកអំបុកនេះ មិនត្រឹមតែដើម្បីបណ្តេញទឹកទៅវិញប៉ុណ្ណោះទេ តែក៏ធ្វើឡើងដើម្បីសុំទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការក្នុងឆ្នាំថ្មីផងដែរ៕





20



